៦




# ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

## និយមន័យ

ការហាមឃាត់ប្រឆាំងនឹងការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌហាមឃាត់ការអនុវត្តច្បាប់នៅពេលបទល្មើសបានកើតឡើងមុនពេលច្បាប់ចូលជាធរមាន។ ម្យ៉ាងទៀត ច្បាប់ព្រហ្មទណ្ឌអាចអនុវត្តទៅលើបទល្មើសណាដែលបានប្រព្រឹត្តបន្ទាប់ពីច្បាប់នោះចូលជាធរមាន និងកំណត់ការប្រព្រឹត្តបែបនោះថាជាបទល្មើស។

ការហាមឃាត់នេះចេញមកពីគោលការណ៍នីត្យានុកូលភាពដែលបង្កើតឡើងដោយទ្រឹស្តីដូចខាងក្រោម៖



ទ្រឹស្តី គ្មានបទល្មើស គ្មានទោស ត្រូវបានបកស្រាយយ៉ាងច្បាស់ថា "គ្មានទេបទល្មើស បើគ្មានច្បាប់ចែង" មានន័យថាជនណាម្នាក់មិនបានប្រព្រឹត្តបទល្មើសទេ ប្រសិនបើអំពើល្មើសនោះមិនបានចែងដោយច្បាប់។



ទ្រឹស្តី គ្មានបទល្មើស គ្មានទោស ត្រូវបានបកស្រាយយ៉ាងច្បាស់ថា"គ្មានទេទោស បើគ្មានច្បាប់ចែង" មានន័យថាការផ្តន្ទាទោសលើជនណាម្នាក់បានលុះត្រាតែទោសនោះមានចែងយ៉ាងច្បាស់ក្នុងច្បាប់។ លើសពីនេះ តុលាការមិនអាចដាក់ទោសធ្ងន់ជាងទោសដែលមានចែងក្នុងច្បាប់ជាធរមាន នៅពេលដែលបទល្មើសនោះបានប្រព្រឹត្ត។

គោលការណ៍នីត្យានុកូលភាពមានន័យជារួមថា លុះត្រាតែច្បាប់បានកំណត់អំពីបទល្មើស និងទោសប៉ុណ្ណោះ ទើបអាចផ្តន្ទាទោសបាន។ ផលវិបាក៖

មិនមាននរណាម្នាក់ត្រូវបានកាត់ទោស និងថាមានពិរុទ្ធភាពពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើមិនបានចែងដាក់លាក់ក្នុងច្បាប់ព្រហ្មទណ្ឌ នៅពេលអំពើនោះបានកើតឡើង។

ទោះបីជារកឃើញថា មានពិរុទ្ធភាពពីបទល្មើសព្រហ្មទណ្ឌក៏ដោយ ជនដែលមានពិរុទ្ធភាពមិនអាចដាក់ទោសបានឡើយ ប្រសិនបើទោសនោះមិនបានកំណត់ដោយច្បាប់ និងមិនអាចដាក់ទោសបានទេប្រសិនបើទោសនោះធ្ងន់ជាងទោស ដែលបានចែងដោយច្បាប់នៅពេលបទល្មើសបានប្រព្រឹត្ត។

# ក្របខ័ណ្ឌច្បាប់

## ច្បាប់អន្តរជាតិ



ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌត្រូវបានហាមឃាត់យ៉ាងច្បាស់តាមច្បាប់អន្តរជាតិ នៅមាត្រា ១១(២) នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស "គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌដោយបានប្រព្រឹត្ត ឬភ្លាំងភ្លាត់ប្រព្រឹត្ត ដែលអំពើនេះមិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិ។ មិនត្រូវផ្តន្ទាទោសឱ្យធ្ងន់ជាងទោស ដែលបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេលបទល្មើសបានកើតឡើងឡើយ"។ ហើយសិទ្ធិនេះក៏បានការពារដោយមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

## ច្បាប់ជាតិ

ការហាមឃាត់ប្រឆាំងអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌត្រូវបានធានាដោយក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាក្នុងមាត្រា ៣ បានចែងថា "មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះ មានចែងនៅក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបផ្តន្ទាទោសព្រហ្មទណ្ឌបាន។" ហើយសិទ្ធិក៏បានចែងនៅក្នុងមាត្រា ៩ និងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជានេះផងដែរ។



## សារសំខាន់

ការហាមឃាត់ប្រឆាំងអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌគឺមានសារសំខាន់ព្រោះគោលការណ៍នេះជួយពង្រឹងគោលការណ៍នីត្យានុកូលភាព និងជាមូលដ្ឋាននៃនីតិរដ្ឋ ដែលគោលការណ៍នេះកំណត់ថាបទល្មើសព្រហ្មទណ្ឌត្រូវតែបញ្ញត្តដោយច្បាប់។



ភាពត្រឹមត្រូវនៃស្ថាប័នតុលាការគឺការពារបុគ្គលពីការកាត់ទោស ការដាក់ទោស និងទណ្ឌកម្មតាមអំពើចិត្ត។



ភាពប៉ានប្រមាណជាមុនដោយច្បាប់ ដោយដឹងថា អំពើសកម្ម និងអំពើអកម្មណាមួយអាចបណ្តាលឱ្យបុគ្គលទទួលខុសត្រូវ ពីបទល្មើសព្រហ្មទណ្ឌ និងទោសស្របតាមឥរិយាបថរបស់ជននោះបានប្រព្រឹត្ត។

## ដែនកំណត់

១ យោងតាមមាត្រា ៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ការហាមឃាត់ប្រឆាំងនឹងអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ មិនអាចត្រូវបានដកហូតនៅអំឡុងពេលរដ្ឋស្ថិតនៅក្នុងភាពអាសន្ន។

២ ទោះបីជាយ៉ាងនេះក្តីច្បាប់អន្តរជាតិកំណត់ករណីលើកលែង៖ ការអនុវត្តប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌត្រូវបានអនុញ្ញាតចំពោះច្បាប់ព្រហ្មទណ្ឌដែលមានអនុគ្រោះ និងជាប្រយោជន៍ដល់ជនជាប់ចោទ។ (ឧទាហរណ៍៖ ច្បាប់ដែលលុបបទល្មើស សកម្មភាព ច្បាប់ដែលចែងអំពីទោសស្រាលជាង ។ល។)។

៣ ការហាមឃាត់ប្រឆាំងនឹងអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ អនុវត្តតែចំពោះច្បាប់ដែលមានការផ្លាស់ប្តូរនៃកម្រិតទោសនៃអំពើណាមួយប៉ុណ្ណោះ ដោយមិនមានផលប៉ះពាល់ដល់នីតិវិធី ឬវិធានភស្តុតាង និងមិនប៉ះពាល់ដល់ប្រភេទនៃបទល្មើសឡើយ។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

Sweden Sverige

People Change the World Diakonia

CC BY NC SA